ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៤៧៨
ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០០
**<u>សាលដីកា</u>**
លេខៈ៩២
ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០១

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០១ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ........... ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក ...............ជាចៅក្រម
៥-លោក ............. ជាចៅក្រម
៦-លោក ................. ជាចៅក្រមចៅក្រមរបាយការណ៍
៧-លោក ............. ជាចៅក្រម
៨-លោក ............. ជាចៅក្រម
៩-លោក ................. ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោក .................

**<u>តំណាងមហាអយ្យការ</u>**

-លោក ................. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៨៤(ក) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០នៃសំណុំរឿងរដ្ឋប្បវេណីលេខ៥១ ចុះថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះឪសព ភេទស្រីអាយុ ២៨ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅក្រុមទី១៣ មណ្ឌល១ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។ ឪពុកឈ្មោះឪ ឡេន(រ) ម្តាយឈ្មោះ ហូរ (រ) ។

និងចុងបណ្តឹងសាទុក្ខឈ្មោះហសភេទប្រុសអាយុ៤០ឆ្នាំ ជាតិខ្មែរមុខរបរ នៅផ្ទះមានទីលំនៅក្រុមទី១០ មណ្ឌល២ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ។ ឪពុកឈ្មោះហ៊ន មួយ(ស)ឈ្មោះយទ (ស)។

តតិយជនឈ្មោះយទទីលំនៅក្រុមទី១០ មណ្ឌល២ សង្កាត់មិត្តភាព ក្រុងព្រះសីហនុ(ស)។ ដែលមានឈ្មោះ ភហជាតំណាង ។

**អំពីវិវាទ :** ប្តឹងសុំផ្តាច់សមគ្គសង្វាស សុំសិទ្ធិគ្រប់គ្រងកូន សុំអាហារកិច្ចចិញ្ចឹមកូន និងសិទ្ធបែងចែកទ្រព្យសម្បត្តិរួម ។

បានឃើញបណ្តឹងសាទុក្ខលេខ៤២១ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០ របស់អ្នកស្រីឌសព ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ៨៤(ក) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ៤៧៨ ចុះថ្ងៃទី២៨ ខែធ្នូឆ្នាំ២០០០ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៩-១០-១៩៩៥ របស់ដើមចោទឈ្មោះឌសព ប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តីឈ្មោះហស, សុំសិទ្ធិគ្រប់គ្រងកូន, សុំអាហារកិច្ចចិញ្ចឹមកូន និងសុំបែងចែកទ្រព្យសម្បត្តិរួម ដោយអាងហេតុថា ខ្លួនបានរៀបការជាមួយនឹងឈ្មោះហស នៅឆ្នាំ១៩៩១ ហើយរស់នៅជាមួយគ្នារហូតដល់សព្វថ្ងៃមានកូនស្រី០១នាក់ ។ ក្រោយពីរៀបការហើយខ្លួនពុំដែលស្គាល់នូវសុភមង្គលទេ គឺរស់ទាំងបង្ខំក្រោមការមើលងាយមើលថោកពីសំណាក់ក្រុមគ្រួសារ និងបងប្អូនរបស់ប្តីខ្លួន ហើយការដោះស្រាយ ជីវភាពរស់នៅប្រចាំថ្ងៃ រួមទាំងកូន០៤នាក់ ដែលជាកូនដើមរបស់ហស គឺខ្លួនជាអ្នកទទួលបន្ទុករាប់រងទាំងអស់ ។ ខ្លួនអស់មនោសញ្ចេតនា និងរួមរស់ជាមួយគ្នាជាប្តីប្រពន្ធតទៅទៀតបានហើយ ទើបខ្លួនប្តឹងមកនេះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១២៧ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៦ របស់តុលាការក្រុងព្រះសីហនុ សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី០២-១១-៩៥ របស់អ្នកស្រីឌសព (ដើមចោទ) ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ឱ្យអ្នកស្រី ឌសព និងលោក ហសដាច់សមគ្គសង្វាសពីគ្នា តាមការព្រមព្រៀង របស់គូភាគី ចាប់ពីថ្ងៃនេះតទៅ ។

៣- ឱ្យអ្នកស្រីឌសព ស្ថិតក្នុងភាពមេម៉ាយ ចំនួន៣០០ថ្ងៃ ចាប់ពីថ្ងៃនេះតទៅ ។

៤- កូន១នាក់ឈ្មោះគជភេទស្រីអាយុ ៤ឆ្នាំ ត្រូវប្រគល់សិទ្ធិឱ្យអ្នកស្រីឌសព គ្រប់គ្រងចាប់តាំងពីថ្ងៃនេះ តទៅ តែត្រូវឱ្យលោកហសចេញប្រាក់អាហារកិច្ចចិញ្ចឹមកូននេះ ជាប្រាក់ចំនួន៥០០០០៛ ក្នុង១ខែគិតចាប់តាំងពីដំណាច់ខែធ្នូឆ្នាំ១៩៩៦ នេះតទៅ រហូតដល់កូនធំពេញវ័យ ។ មាតាបិតា មានករណីយកិច្ចអប់រំបីបាច់ថែរក្សាចិញ្ចឹមកូនឱ្យបានល្អតាមមាត្រា១១៥ នៃច្បាប់ស្តីពីអាពាហ៍ និងគ្រួសារ ។

៥-ទ្រព្យសម្បត្តិរួមមានផ្ទះ១ល្វែង ទំហំ ១៦,២០ម គុណ ៤,៥ម ដែលមានឈ្មោះយទជាម្តាយចុងចម្លើយជាម្ចាស់កម្មសិទ្ធិ ដែលមានព្រំប្រទល់ខាងជើងទល់នឹងផ្លូវទៅផ្សារលើ ខាងកើតជាប់នឹងផ្ទះឈ្មោះភហខាងលិចជាប់ផ្ទះឈ្មោះដផ ខាងត្បូងជាប់នឹងដីឈ្មោះធូ ផុក ស្ថិតនៅក្នុងក្រុមទី១០ មណ្ឌល២ សង្កាត់

៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ត្រូវបែងចែកជាពីរចំណែកស្មើគ្នា ចាប់តាំងពីថ្ងៃដែលសាលក្រមនេះមានអានុភាពអនុវត្តតទៅ ។

៦- ទុកសិទ្ធិឱ្យចុងចម្លើយទៅសួរសុខទុក្ខដល់កូនបាន ។

៧- ឱ្យលោកហាសបង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ បូករួម៧០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់៧០០០៛ ដែលដើមចោទបានបង់រួចហើយ ។ កាលបើហួសឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយ សងប្រាក់៧.០០០៛ ទៅដើមចោទវិញ ។

សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៦ របស់ឈ្មោះហាសប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១២៧ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៦ របស់តុលាការក្រុងព្រះសីហនុ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧១ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍សម្រេចចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ៣០ ចុះថ្ងៃទី២៧-១២-៩៦ របស់ឈ្មោះហាសទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទទួលស្គាល់ឈ្មោះយយទតតិយជន (ស្លាប់) ដោយមានឈ្មោះភហានិងប្រពន្ធ ឈ្មោះធសអជាអ្នកស្នងមរតក ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១២៧ ចុះថ្ងៃទី២៥-១២-៩៦ របស់តុលាការក្រុងព្រះសីហនុទុកជាបានការ វៀរលែងតែចំណុចទី៥ នៃសាលក្រមនេះ ត្រូវបដិសេធចោល ។

៤- សម្រេចប្រគល់ផ្ទះទំនាស់ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លីលេខអា៤-៨៣១ ចុះថ្ងៃទី០៣-១១-៩៣ ស្ថិតនៅក្រុមទី១០ មណ្ឌល២ សង្កាត់៤ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ តាមលិខិតបណ្តាំចុះថ្ងៃទី៣០-១២-៩៦ របស់ឈ្មោះយទទៅឱ្យឈ្មោះភហានិងប្រពន្ធឈ្មោះធសអ កាន់កាប់បន្ត តាមច្បាប់តទៅ ។

៥- កាត់យកប្រាក់ប្រដាប់ក្តី នៅជាន់សាលាឧទ្ធរណ៍ចំនួន១៣,០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់ទុករួច គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយក្នុងកិច្ច ប្រគល់ដីកាកោះ ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ៥.០០០៛ សរុប ១៣.០០០៛ ។

៦- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទសម្រេចបើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ២៧ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៨ របស់អ្នកស្រីឳសព ប្តឹងមិនសុខចិត្តពីសាលដីកាលេខ៧១ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ៥៣៤ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលបណ្តឹងទាស់លេខ២៧ ចុះថ្ងៃទី២៩-០៦-៩៨ របស់ឈ្មោះឳសព ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់ នឹងគតិច្បាប់ ។

២- តម្កល់សាលដីកាកំបាំងមុខលេខ៧១ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទំងមូល ។

៣- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តីបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣១១ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៨ របស់អ្នកស្រីឳ ស្រីពៅ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៥៣៤ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តី សម្រេចទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ១៤៦ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៩ របស់តុលាការកំពូល សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលបណ្តឹងសាទុក្ខលេខ៣១១ ចុះថ្ងៃទី១៣-០៨-៩៨ របស់អ្នកស្រីឳសព ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ៥៣៤ ចុះថ្ងៃទី១៣-០៨-៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣១៥ ចុះថ្ងៃទី១៦-១០-៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីដែលអ្នកស្រីឳ ស្រីពៅ បានបង់ទុកនៅតុលាការកំពូលចំនួន១៩០០០រៀលគឺ:

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយក្នុងការប្រគល់ដីកាកោះ ចំនួន១៥.០០០រៀល សរុប ១៩០០០រៀល ។ ហើយតម្រូវ ឲ្យលោកហសសងប្រាក់ចំនួន១៩០០០រៀល នេះទៅអ្នកស្រីឳសព វិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៩ ។

បានឃើញ ដីកាបញ្ជូនលេខ៣០១/៩៩សរណ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៨៩ របស់តុលាការកំពូល បង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍វិញ ដើម្បីចាត់ការតាមច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៨៤(ក) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលជំនុំជំរះរឿងក្តីនេះ ជាលើកទីII តាមអំណាចសាលដីកាលេខ១៤៦ ចុះថ្ងៃទី១៩-៨-៩៩ របស់តុលាការកំពូល ។

២- បញ្ជូនឈ្មោះភហមកក្នុងរឿងក្តីនេះ ខាងចុងចម្លើយ ។

៣- ប្រគល់ផ្ទះទំនាស់ដែលមានប័ណ្ណសំគាល់សិទ្ធិប្រើប្រាស់ដីធ្លីលេខ$A_4$ ៣៨១ ចុះថ្ងៃទី០៣-១១-៩៣ ស្ថិតនៅក្រុម១០ មណ្ឌល០២ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ឱ្យទៅឈ្មោះភហនិងប្រពន្ធឈ្មោះធសអ កាន់កាប់ជាកម្មសិទ្ធិ ចាប់ពីពេលសាលដីកានេះចូលជាស្ថាពរ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បាន បង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជី៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥០០០៛ និងអង្វាធរតុលាការ៥០០០៛ សរុប១៣០០០៛ ។

៥- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវសាទុក្ខក្នុង កំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៤២១ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០ របស់អ្នកស្រីឱសព ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៨៤(ក) ចុះថ្ងៃទី១៩ ខែតុលាឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០១ របស់ឈ្មោះឱសព

បានឃើញសារណាតប ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់ឈ្មោះ ភហ

បានឃើញសារណាតប ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់ឈ្មោះ ហស

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ ថា

-បណ្តឹងសាទុក្ខរបស់ដើមចោទស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះពិនិត្យ ពិចារណា ។

សាលដីកា រដ្ឋប្បវេណីលេខ៨៤(ក) ចុះថ្ងៃទី១៩-១០-២០០០ របស់សាលាឧទ្ធរណ៍ សម្រេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាសម្រេច ទាំងអង្គហេតុ ទាំងអង្គច្បាប់ ។

បានស្តាប់ចម្លើយរបស់អ្នកស្រីឱសព ឆ្លើយថា សាលាឧទ្ធរណ៍ កាត់សេចក្តីមកនេះដោយមានភាពមិនត្រឹមត្រូវតាមច្បាប់ឡើយ ព្រោះទ្រព្យសម្បត្តិដែលខ្លួន រកស៊ីតាំងពីមុនមក ហើយផ្ទះនេះក៏បានចាក់

សោរមិនឱ្យខ្លួនចូលនៅដែរ ផ្ទះនេះជារបស់ដែលខ្លួន និងគាត់នេះខំរកទាំងអស់គ្នា ហេតុអ្វីបានជា គាត់មិនឱ្យខ្លួនចូលទៅជិត ហើយចាក់សោរចោលទៀត ដោយទុកឱ្យខ្លួនរស់នៅក្នុងផ្ទះជួលគេទៅវិញ? សូមលោកមេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង ។ គាត់ចេញទៅសមុទ្ររកស៊ីមិនបានណាស់ណាទេ ផ្ទះនេះសង់ហើយ នៅឆ្នាំ៩៣-៩៤ ។

បានស្តាប់ចម្លើយរបស់លោកហសឆ្លើយតបថាៈ ខ្លួនគ្មានប្រាក់ឯណាមកសង់ផ្ទះ ព្រោះខ្លួនលក់តែបបរសបន្តិចបន្តួចសម្រាប់ចិញ្ចឹមជីវិតប៉ុណ្ណោះ ពាក្យដែលគេបានលើកឡើងមកនេះ គឺជាពាក្យបំភ្លើសទាំងអស់ ខ្លួនសុំបដិសេធមិនទទួលស្គាល់ទេ ដោយខ្លួនមានតែមួយតម្លឹងកន្លះសម្រាប់ការប្រពន្ធតែប៉ុណ្ណោះ ។

បានស្តាប់ចម្លើយរបស់លោកភហាឆ្លើយតបថាៈ ផ្ទះមួយល្វែងនេះ មានឈ្មោះយទជាម្ចាស់កម្មសិទ្ធិ ដែលបានធ្វើអំណោយប្រគល់សិទ្ធិខ្លួន ប័ណ្ណកម្មសិទ្ធិនោះធ្វើឡើងត្រឹមត្រូវតាមច្បាប់ ពុំមានការក្លែង បន្លំឡើយ ផ្ទះនេះខ្លួនសង់ហើយមុនពេលពួកគេមានទំនាស់ទៅទៀត ចំណែកឯប្តីប្រពន្ធគេនេះ មិនដែលរស់នៅក្នុង មណ្ឌលនេះឡើយ សូមឯកឧត្តម មេត្តាពិចារណា និងរកយុត្តិធម៌ឱ្យខ្លួនផង ។

ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់គូភាគី និងតតិយជន

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤២១ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០ របស់អ្នកស្រីឱសព ស្ថិតនៅក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាព របស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីផងដែរ

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ចាត់បញ្ចូលលោកភហាប្អូនចុងចម្លើយជាតតីយជន ខាងចុងចម្លើយ ដោយសំអាងហេតុថា ឈ្មោះនេះជាម្ចាស់ដីទំនាស់ ហើយបានទិញពីឈ្មោះសកហើយបានសង់ផ្ទះ៣ល្វែង និងបានចែកឱ្យម្ចាស់មួយល្វែង មានធ្វើប័ណ្ណកម្មសិទ្ធិស្របច្បាប់ ហើយក្រោយមកទៀតម្តាយបាន ធ្វើបណ្តាំចែកដី និងផ្ទះទំនាស់នេះ ឱ្យទៅឈ្មោះភហនិងនាងឈសអ ជាកូនវិញនោះ ជាការភ័ន្តច្រឡំ ពីព្រោះថា ចម្លើយសាក្សីបំភ្លឺគឺជាម្ចាស់ដីដើមឈ្មោះសកនិងប្រពន្ធឆ្លើយប្រហាក់ប្រហែលគ្នា ដោយខ្លួនបាន ទទួលមាស ខ្សែ ក ខ្សែ ដៃ ពីឈ្មោះភហនាពេលនោះ ចុងចម្លើយឈ្មោះហសនៅជាមួយដែរក៏បានឆ្លើយថាខ្លួនបានដោយកខ្សែ ក ខ្សែ ដៃ ប្រពន្ធគ្មានមាសសន្លឹកទេ ។

- យល់ឃើញថា ចុងចម្លើយយកផ្ទះ និងដីទំនាស់ធ្វើប័ណ្ណដាក់ឈ្មោះ អ្នកស្រី យទជាម្ចាស់ដែលមានអាយុជាង៨០ឆ្នាំហើយ ដែលគ្មានពាក់ព័ន្ធជាមួយប្តីប្រពន្ធសោះនោះ គឺជាទង្វើបង្វែរទ្រព្យសម្បត្តិរួមរវាងប្តីប្រពន្ធ ដើម្បីជៀសការទាមទារពីដើមចោទដែលផ្ទុយនឹងមាត្រា៣៥នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារតែ ប៉ុណ្ណោះ ។

- យល់ឃើញថា តាមលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០-០៥-៩២ លោកសកនិងអ្នកស្រីមដល បានប្រគល់ដីសង់លំនៅស្ថានឱ្យបងប្អូន ៣នាក់ គឺកហ, ធុំ ចាន់ជីវុន និងហ៊ិន សឿន (ហស ) ដូច្នេះ ដីនេះត្រូវមួយផ្នែកជាទ្រព្យសម្បត្តិរួមរបស់ស្ត្រីប្រពន្ធហស និងឪសព ពុំមែនជា ទ្រព្យសម្បត្តិរបស់អ្នកស្រី យទទេ ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៥៣៤ ចុះថ្ងៃទី១៣-០៨-៩៨ របស់សាលាឧទ្ធរណ៍ ត្រូវបានតុលាការកំពូលទុកជាមោឃៈទាំងមូល និងបង្វិលឱ្យសាលាឧទ្ធរណ៍ជំនុំជំរះជាថ្មីឡើងវិញ ។ ប៉ុន្តែក្នុងការជំនុំជំរះ លើកក្រោយតាមសាលដីកាលេខ៨៤(ក) ចុះថ្ងៃទី១៩-១០-២០០០ សាលាឧទ្ធរណ៍ ពុំបានសម្រេច អំពីការផ្តាច់សមគ្គសង្វាស អំពីអំណាចមេបា និងអាហារកិច្ចចិញ្ចឹមកូនទេ ។ ដូច្នេះ តុលាការកំពូល ត្រូវសម្រេចឡើង វិញទាំងអស់ពីបញ្ហានេះ ។

- យល់ឃើញថា ដើមចោទ និងចុងចម្លើយមានកូនស្រីម្នាក់ សព្វថ្ងៃស្ថិតក្នុងបន្ទុកដើមចោទជាម្តាយគ្រប់គ្រង ដូច្នេះគប្បីតុលាការពិចារណាអំពីករណីនេះ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៨៤(ក) ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**និច្ឆ័យសេចក្តីចំពោះមុខគូភាគី**

១- ទទួលបណ្តឹងសាទុក្ខលេខ៤២១ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០ របស់អ្នកស្រីឪសពទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

២- ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ៨៤(ក) ចុះថ្ងៃទី១៩-១០-២០០០ របស់សាលាឧទ្ធរណ៍។

៣- បដិសេធឈ្មោះកហចេញពីតតិយជននៃ រឿងក្តីនេះ ។

៤- ឱ្យអ្នកស្រីឪសព និងលោកហស ដាច់សមគ្គសង្វាស ពីគ្នាតាមការព្រមព្រៀង។

៥- ឱ្យអ្នកស្រីឪសព ស្ថិតនៅក្នុងភាពមេម៉ាយ៣០០ថ្ងៃ ចាប់ពីថ្ងៃនេះតទៅ ។

៦- ប្រគល់កូនស្រី០១ នាក់ឈ្មោះគជ ឱ្យអ្នកស្រីឪសព គ្រប់គ្រងចាប់ពីថ្ងៃនេះតទៅ ប៉ុន្តែតម្រូវឱ្យលោកហស ចេញអាហារកិច្ចចិញ្ចឹមកូនក្នុង១ខែចំនួន៥០.០០០រៀល គិតចាប់ពីខែធ្នូ ឆ្នាំ ១៩៩៦ តទៅ

រហូតដល់កូនមាននីតិភាព ។ មាតាបីតា មានករណីយកិច្ចអប់រំថែរក្សាចិញ្ចឹមកូនឱ្យបាន ល្អ តាមមាត្រា ១១៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ហើយទុកសិទ្ធិឱ្យចុងចម្លើយទៅសួរសុខទុក្ខ ដល់កូនបាន ។

៧-ទុកជាមោឃៈ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីធ្លីលេខ$A_4$ ៨៣១ ចុះថ្ងៃទី០៣-១១-៩៣ ។

៨-ទ្រព្យសម្បត្តិរួមមានផ្ទះ១ល្វែងទំហំ១៦២០មx៤,៥០ម និងដីទំហំ០អា ៨២ សង់ទីអា ដែលសង់ផ្ទះនេះ ដែលមានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវទៅផ្សារលើ ខាងកើតជាប់ និងផ្ទះឈ្មោះភហខាងលិចជាប់ផ្ទះឈ្មោះដផ ខាងត្បូងជាប់ និងដីឈ្មោះអផ ស្ថិតនៅក្នុងក្រុមទី១០ មណ្ឌល២ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ត្រូវបែងចែកជាពីរចំណែកស្មើគ្នា ឱ្យលោកហស និង អ្នកស្រី ឌសព ។

៩- រឹបអូសប្រាក់ប្រដាប់ក្តីដែលឈ្មោះឌសព បានបង់ទុកនៅតុលាការកំពូលចំនួន១៩០០០រៀល គឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន៨០០រៀល សម្រាប់ ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយក្នុងការប្រគល់ដីកាកោះចំនួន១៥០០០រៀល សរុប១៩០០០រៀល ហើយបង្គាប់ឱ្យ ចុងចម្លើយសងប្រាក់ចំនួន១៩០០០រៀល ទៅឱ្យដើមចោទ វិញ ។

១០- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០០១ ។